ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៨.១៣-០១៧-០០៣ គ្រ.ភ-៣.ទ.ប

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំស្តីពី "តួនាទីនិងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា"

**រាជធានីភ្នំពេញ ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧**

ធនាគារជាតិនៃកម្ពុជា បានរៀបចំកិច្ចប្រជុំស្តីពី "តួនាទីនិងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា" ក្រោមអធិបតីភាព លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ដោយមានការអញ្ជើញចូលរួមពីថ្នាក់នាយកប្រតិបត្តិនិងហេរញ្ញិក មកពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ ក្រេឌីតប្យូរ៉ូ និងអាជីវករប្តូរប្រាក់ប្រមាណ២០០ រូប។

គោលបំណងចម្បងនៃកិច្ចប្រជុំនេះ គឺដើម្បីបង្កើតជាវេទិកាសម្រាប់ឱ្យតំណាងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា បានជួបពិភាក្សាគ្នាលើវឌ្ឍនភាពថ្មីៗ និងគោលនយោបាយដែលធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្ត ព្រមទាំងកាតព្វកិច្ចនិងការរួមចំណែករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងដំណើរការអភិវឌ្ឍវិស័យធនាគារកម្ពុជា ឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព ស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ និងគោលនយោបាយអភិវឌ្ឍន៍វិស័យនានារបស់រាជរដ្ឋាភិបាល។

កិច្ចប្រជុំបានប្រព្រឹត្តទៅដោយជោគជ័យនិងផ្លែផ្កា ដោយថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ បានពិភាក្សាផ្លាស់ប្តូរយោបល់លើចំណុចដែលពាក់ព័ន្ធនឹង ៖ i/- ការផ្តល់សេវាធនាគារកណ្តាល ii/- ការអភិវឌ្ឍប្រព័ន្ធទូទាត់ iii/- ការប្រមូលនិងការផ្សព្វផ្សាយទិន្នន័យស្ថិតិ iv/- ការអនុវត្តគោលនយោបាយរូបិយវត្ថុ និង v/- យន្តការត្រួតពិនិត្យវិស័យធនាគារ។

**ទំនាក់ទំនង៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh